# ខ្លឹមសារជំនឿលើព្រះយេស៊ូវគ្រីស្ទ ក្នុង៦មេរៀន

## មេរៀនទី៥ ព្រះបានរៀបផ្លូវឲ្យមនុស្សដែលគ្មានផ្លូវ ឲ្យជានានឹងព្រះអង្គបាន

លំនាំដើម

សេចក្តីស្រលាញ់របស់ព្រះទៅកាន់មនុស្សអស្ចារ្យពីព្រោះមនុស្សមិនសមនឹងទទួលសេចក្តីស្រលាញ់របស់ព្រះទេ។ យើងទាំងអស់គ្នាជាអ្នកមានបាប មានទោស ជាអ្នកបះបោប្រឆាំងនឹងព្រះ។ ចាប់តាំងពីលោកអ័ដាម និងនាងអេវ៉ាមក រហូតដល់ថ្ងៃនេះ មនុស្សយើងមិនបានបានគោរពព្រះ មិនស្រលាញ់ទ្រង់ មិនប្រព្រឹត្តតាមក្រិត្តវិន័យរបស់ព្រះទេ។ យើងទាំងអស់គ្នាជាអ្នករមិលគុណព្រះប៉ុណ្ណោះ។

ប៉ុន្តែព្រះនៅតែ «**ស្រឡាញ់មនុស្សលោកជាខ្លាំង**» យ៉ូហាន ៣:១៦

ទោះបីជាព្រះស្រឡាញ់មនុស្សយ៉ាងណាក៏ដោយ មានបញ្ហាមួយដ៏ធំដែរ គឺព្រះអង្គបរិសុទ្ធ ហើយយុត្តិធម៌។ អំពើបាបត្រូវតែសង។ មនុស្ស

បានដាច់ចេញពីព្រះហើយ។ ហើយ «**ឈ្នួលរបស់បាប ជាសេចក្តីស្លាប់**» រ៉ូម ៦:២៣

មានសំនួរពីរ គឺ

១) តើយើងធ្វើយ៉ាងម៉េចដើម្បីជានានិងព្រះអង្គបាន?

២) តើមានអំពើល្អអ្វីខ្លះ ដែលយើងធ្វើបាន ដើម្បីលប់ទោសបាបរបស់យើងកើត?

ចំឡើយសម្រាប់សំនួរទី១ គឺគ្មានអ្វីដែលយើងធ្វើបានដើម្បីជានានឹងព្រះអង្គបានទេ។ យើងទាំងអស់គ្នាសមនឹងទទួលសេចក្តីស្លាប់ និងឋាននរគរួចទៅហើយ។ ព្រះយេស៊ូវបានពណ៌នាអំពីឋាននរគថា ឋាននរគជាកន្លែង

«**យំ ហើយសង្កៀតធ្មេញ**» ម៉ាថាយ ២៤:៥១

«**ទីងងឹតខាងក្រៅ**» ពីឋានសួគ ម៉ាថាយ ២៥:៣០

«**ពួកអ្នកទាំងនោះ នឹងចេញទៅទទួលទោសអស់កល្បជានិច្ច**»

ម៉ាថាយ ២៤:៤៦

**«ភ្លើងដែលឆេះអស់កល្បជានិច្ច»** ម៉ាថាយ ១៨:៨

**«ភ្លើងនរក»** ម៉ាថាយ ១៨:៩

តើអំពើបាបអាក្រក់ប៉ុនណា? វាអាក្រក់ដល់សមនឹងទទួលការរងទុក្ខវេទនានៅឋាននរកអស់កល្បជានិច្ច! នេះហើយជាសេចក្ដីយុត្តិធម៌។

យើងមិនចាប់ជាតិទេ! យើងមានជីវិតតែមួយនៅលើផែនដីនេះ ហើយជីវិតរបស់យើងតែមួយនេះ ខូច រលួយហើយដោយព្រោះបាប។

ចំទ្បើយសម្រាប់សំនួរទីពីរដែលខ្ញុំបានសួរ គឺទេ! យើងមិនអាចធ្វើអំពើល្អល្មម ឬកែខ្លួនឡើងល្មម លទ្ធផលសងថ្លៃលោះបាបរបស់ខ្លួនបានទេ។

ព្រះយេស៊ូវមានបន្ទូលថា **«ពួកអ្នកទាំងនេះនឹងចេញទៅទទួលទោសអស់កល្បជានិច្ច រីឯពួកមនុស្សសុចរិតនឹងចូលទៅទទួលជីវិតអស់កល្បជានិច្ចវិញ»** ម៉ាថាយ ២៥:៤៦

តើយើងអាចខំប្រឹងកែខ្លួនទៅជាមនុស្សសុចរិតបានទេ? ទេ!

**«គ្មានអ្នកណាសុចរិតឡើយ សូម្បីតែម្នាក់ក៏គ្មានផង»** រ៉ូម ៣:១០

**«ខ្លួនទីពឹងខ្លួន» មិនបានឡើយ!**

ប៉ុន្តែ **«ព្រះស្រឡាញ់មនុស្សលោកជាខ្លាំង»** យ៉ូហាន ៣:១៦

ម្ល៉ោះហើយ ព្រះសម្រេចព្រះហឫទ័យរៀបផ្លូវមួយ ដើម្បីសង្គ្រោះមនុស្សឲ្យរួចពីទោសបាប ប្រយោជន៍ជានានឹងព្រះអង្គបាន។

ចាប់ទាំងពីលោកអ័ដាម និងនាងអេវ៉ា ប្រព្រឹត្តិបាបដំបូង ព្រះមានព្រះបន្ទូលទំនាយអំពីព្រះអង្គសង្រគោះដែលត្រូវយាងមកសង្គ្រោះមនុស្សលោក។ ២០២០ឆ្លៃឆ្នាំមុន ព្រះអង្គសង្គ្រោះនោះបានយាងមក គឺព្រះរាជបុត្រារបស់ព្រះ គឺព្រះយេស៊ូវគ្រីស្ទ។